# ព្រះរាជក្រម

នស/រកម/០៦១៣/០០៩

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី៣ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE

# ច្បាប់
# ស្តីពី
# វិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**មាត្រា មួយ.-**

មាត្រា២៤៧ (ដីកាដំណោះស្រាយ) មាត្រា៣៦៨ (រយៈពេលសម្រាប់ធ្វើបណ្តឹងទាស់) មាត្រា៣៧២ (បណ្តឹងទាស់ដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី) និងមាត្រា៣៨២ (រយៈពេលប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី) នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

## មាត្រា ២៤៧ថ្មី.- ដីកាដំណោះស្រាយ

ចៅក្រមស៊ើបសួរបិទការស៊ើបសួរតាមដីកាដំណោះស្រាយ។ ដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះឬដីកាលើកលែងចោទប្រកាន់ ។

ប្រសិនបើយល់ឃើញថាអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ។ ដីកាត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់ ។

ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់នៅក្នុងករណីដូចតទៅ ៖

១- អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ។

២- ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ ។

៣- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ។

៤- ករណីដែលបណ្តឹងអាជ្ញារលត់ ។

ដីកាដំណោះស្រាយជានិច្ចកាលត្រូវតែមានសំអាងហេតុ ។ ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ ។ ដីកាអាចជាដីកាបញ្ជូនទៅតុលាការជំនុំជម្រះចំពោះអំពើមួយចំនួន និងជាដីកាលើកលែងចោទប្រកាន់ចំពោះអំពើដទៃទៀត ។

ក្នុងករណីដែលសំណុំរឿងស៊ើបសួរពាក់ព័ន្ធនឹងអង្គហេតុច្រើន ចៅក្រមស៊ើបសួរអាចចេញដីកាដំណោះស្រាយចំពោះអង្គហេតុដែលការស៊ើបសួរបានចប់សព្វគ្រប់ និងបន្តការស៊ើបសួរចំពោះអង្គហេតុផ្សេងទៀតបាន។ ចៅក្រមស៊ើបសួរក៏អាចចេញដីកាលើកលែងចោទប្រកាន់ចំពោះជនត្រូវចោទដែលត្រូវបានស៊ើបសួររកឃើញថា មិនមានការពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស ឬការចូលរួមប្រព្រឹត្តបទល្មើស និងធ្វើការស៊ើបសួររកអត្តសញ្ញាណជនល្មើសបន្តទៀតបាន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ដីកាដំណោះស្រាយត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។

ក្នុងករណីដែលមានការលើកលែងចោទប្រកាន់ដោយមូលហេតុអត្តសញ្ញាណរបស់ជនត្រូវចោទមិនត្រូវបានស្គាល់ ឬក្នុងករណីដែលជនត្រូវចោទទទួលមរណភាព ចៅក្រមស៊ើបសួរអាចប្តឹងសុំទៅតុលាការព្រហ្មទណ្ឌតាមដីកាបញ្ជូនឲ្យសម្រេចរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុនឬទ្រព្យសម្បត្តិ ប្រសិនបើមានការសង្ស័យដោយសមហេតុផលថា ឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិទាំងនោះពាក់ព័ន្ធនឹងបទល្មើស ។ ក្នុងករណីនេះ តុលាការព្រហ្មទណ្ឌត្រូវសម្រេចអំពីការរឹបអូសដោយសាលក្រមក្នុងសវនាការជាសាធារណៈ ដោយមានការចូលរួមពីតំណាងអយ្យការនិងបុគ្គលពាក់ព័ន្ធ ប្រសិនបើមាន ។ សាលក្រមដែលសម្រេចអំពីការរឹបអូសត្រូវបិទផ្សាយនៅទីកន្លែងដែលតុលាការបានចេញសាលក្រម និងផ្សាយជាសាធារណៈតាមសារព័ត៌មានឬមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ឬដែលអះអាងថាខ្លួនជាម្ចាស់នៃវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស មានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនោះបានក្នុងរយៈពេល ១ (មួយ) ខែ គិតពីថ្ងៃប្រកាសសាលក្រម ប្រសិនបើបុគ្គលនេះបានចូលរួមនៅក្នុងនីតិវិធីនៃការជំនុំជម្រះរបស់តុលាការ និងក្នុងរយៈពេល២ (ពីរ) ខែ គិតពីថ្ងៃប្រកាសផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ប្រសិនបើបុគ្គលនេះមិនបានចូលរួមនៅក្នុងនីតិវិធីតុលាការ ។ បែបបទ និងនីតិវិធីនៃការប្តឹងឧទ្ធរណ៍នេះត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា ៣៦៨ថ្មី.– រយៈពេលសម្រាប់ធ្វើបណ្តឹងទាស់**

បណ្តឹងទាស់ត្រូវតែធ្វើនៅក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ផ្តើមគិត ៖

- ពីថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ឲ្យពិរុទ្ធជនដោយផ្ទាល់ដៃ ឬ
- ពីថ្ងៃដែលពិរុទ្ធជននេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះ មិនបានប្រគល់ឲ្យដល់ពិរុទ្ធជនដោយផ្ទាល់ដៃទេ ។ ពិរុទ្ធជនត្រូវចាត់ទុកថា បានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម ក្នុងករណីដែលនីតិវិធីនៃការឲ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវស្របតាម

ROYAUME DU CAMBODGE CABINET ... MINISTRE DU PALAIS ROYAL

បទប្បញ្ញត្តិដែលមានចែងក្នុងគន្ថីទី៧ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹង) មាតិកាទី៤ (ដីកាឲ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ) នៃក្រមនេះ ។

**មាត្រា ៣៧២ថ្មី.- បណ្តឹងទាស់ដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី**

ដើមបណ្តឹងរដ្ឋប្បវេណីក៏អាចប្តឹងទាស់នឹងសាលក្រម ដែលសម្រេចដោយកំបាំងមុខខ្លួនបានដែរ ។ បណ្តឹងទាស់នេះ ត្រូវកំណត់ទៅលើសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនៃសាលក្រមតែប៉ុណ្ណោះ ។

បណ្តឹងទាស់ត្រូវធ្វើក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ គិតពី ៖

- ថ្ងៃឲ្យដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមបានប្រគល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ ឬ
- ថ្ងៃដែលដើមបណ្តឹងរដ្ឋប្បវេណីបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ឲ្យដល់ដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃទេ ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវចាត់ទុកថាបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម ក្នុងករណីដែលនីតិវិធីនៃការឲ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងគន្ថីទី៧ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹង) មាតិកាទី៤ (ដីកាឲ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ) នៃក្រមនេះ ។

បណ្តឹងទាស់ត្រូវធ្វើជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ។

ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវតំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ។ អ្នកតំណាងត្រូវមានលិខិតប្រគល់សិទ្ធិឲ្យប្តឹងទាស់ ។

បទប្បញ្ញត្តិនៃមាត្រានេះ ត្រូវយកទៅអនុវត្តលើបុគ្គលដែលតុលាការប្រកាសថា ត្រូវទទួលខុសត្រូវរដ្ឋប្បវេណីផងដែរ ។

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

Ksl

**មាត្រា ៣៨២ថ្មី.- រយៈពេលប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី**

ការប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីត្រូវតែធ្វើក្នុងរយៈពេល១ (មួយ) ខែ ។

កាលណាសាលក្រមនោះជាសាលក្រមចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលប្រកាសសាលក្រម ។

កាលណាសាលក្រមនោះជាសាលក្រមចាត់ទុកជាចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីការឲ្យដំណឹងនេះធ្វើតាមវិធីណាក៏ដោយ ។

កាលណាសាលក្រមនោះជាសាលក្រមកំបាំងមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលផុតកំណត់ប្តឹងទាស់ ។

**មាត្រាពីរ.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៣

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧៥.១៣០៦.៦០៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ

ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ហត្ថលេខា

**អង្គ វង្ស វឌ្ឍានា**

លេខៈ ៥៩៣ស.ណ

**សំណៅ[illegible]ជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ មិថុនា ឆ្នាំ២០១៣

**អគ្គ[illegible]រាជរដ្ឋាភិបាល**

**សយ សុខា**